# ជំពូកទី៥

# ការពិគ្រោះយោបល់សាធារណៈ

Draft

# ជំពូកទី ៥
# ការពិគ្រោះយោបល់សាធារណៈ

## ៥.១ សេចក្តីផ្តើម

ការពិគ្រោះយោបល់ ឬស្ទង់មតិជាសាធារណៈនេះជាផ្នែកមួយដ៏សំខាន់នៃការសិក្សាវាយតំលៃទៅលើផលប៉ះពាល់បរិស្ថាន និងសង្គម ព្រោះវាជាការសិក្សាពីទស្សនៈ និងយោបល់របស់បណ្តាអ្នកពាក់ពន្ធ័ទាំងឡាយក្នុងតំបន់សិក្សា។ ដោយហេតុថាគំរោងវិនិយោគដាំដំណាំកៅស៊ូ និងដំណាំកសិ-ឧស្សាហកម្មរបស់ក្រុមហ៊ុន **សេដ្ឋីកុលា** (SETHIKULA CO., LTD) អាចនឹងធ្វើឱ្យមាននូវហេតុប៉ះពាល់បរិស្ថាន និងសង្គម ទៅដល់សហគមន៍មូលដ្ឋាន និងក្រុមហ៊ុននានាដែលស្ថិតនៅជុំវិញតំបន់សិក្សា។ ក្រុមហ៊ុន **ហ្គ្រីន អ៊ិនវ៉ាយរ៉នមិន គ្រុប** (Green Environment Group Co., Ltd.) ដែលជាក្រុមហ៊ុនឯករាជ្យសិក្សាទៅលើហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានធ្វើការសិក្សាស្រាវជ្រាវ និងវាយតំលៃពីហេតុប៉ះពាល់បរិស្ថានដោយផ្អែកទៅលើច្បាប់ និងបទបញ្ញត្តិនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា និងការរៀបចំជាការស្ទង់មតិសាធារណៈដោយធ្វើការអញ្ជើញអ្នកពាក់ព័ន្ធឱ្យចូលរួមដូចជា អាជ្ញាធរមូលដ្ឋាន សហគមន៍មូលដ្ឋាន និងបណ្តាអ្នកពាក់ព័ន្ធនានា ដើម្បីស្វែងយល់ពីទស្សនៈរបស់អ្នកពាក់ព័ន្ធទាំងនោះដែលជាកត្តាមួយអាចសំរាលនូវសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

## ៥.២ គោលបំណង

ចំពោះគោលបំណងនៃការពិគ្រោះយោបល់ ឬការស្ទង់មតិជាសាធារណៈនេះគឺ :

- កំណត់ទីតាំងនៃគំរោងស្នើសុំដីសម្បទានសេដ្ឋកិច្ចលើការដាំដំណាំកៅស៊ូ និងដំណាំកសិឧស្សាហកម្ម
- ធ្វើការស្ទាបស្ទង់មតិពីបណ្តាអ្នកពាក់ព័ន្ធនានាទៅលើតំបន់សិក្សាស្រាវជ្រាវ
- ស្វែងយល់ពីបញ្ហានានាដែលអាចនឹងបង្កើតឡើងដោយសារគំរោង
- ធ្វើការស្ទាបស្ទង់ និងស្នើសុំសំណូមពរពីអ្នកពាក់ព័ន្ធ និងប្រជាជនមូលដ្ឋាន ចំពោះគំរោង

## ៥.៣ វិធីសាស្ត្រ និងតំបន់គោលដៅ

ដើម្បីឱ្យរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង មានភាពត្រឹមត្រូវ និងច្បាស់លាស់នោះក្រុមការងារ **ហ្គ្រីន អ៊ិនវ៉ាយរ៉នមិន គ្រុប** (Green Environment Group Co., Ltd.) បានប្រើប្រាស់នូវវិធីសាស្ត្រការពិភាក្សាជាក្រុម និងការសំភាសន៍ក្នុងគោលបំណងដើម្បីស្រង់ព័ត៌មាន និងសុំយោបល់ពីអ្នកពាក់ព័ន្ធនានា។ ការសំភាសន៍ត្រូវបានធ្វើដោយផ្តោតទៅលើក្រុមគោលដៅដូចជា :

- មន្ទីរបរិស្ថានខេត្តមណ្ឌលគិរី

Draft

- មន្ទីរកសិកម្មខេត្តមណ្ឌលគិរី
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តមណ្ឌលគិរី
- ខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគិរី
- ផ្នែករដ្ឋបាលព្រៃឈើសែនមនោរម្យ
- ដែនជំរកសត្វព្រៃភ្នំណាមល្យើរ
- សាលាខេត្តមណ្ឌលគិរី
- សាលាស្រុកពេជ្រាដា
- ឃុំប៊ូស្រា (រួមទាំង ភូមិពូលុ ភូមិឡាំមេះ ភូមិប៊ូស្រា ភូមិពូទីត ភូមិពូរាំង និងពូចារ)
- សាលាស្រុកអូររាំង
- ឃុំដាក់ដាំ

## ៥.៤ លទ្ធផលនៃការពិភាក្សា

បណ្តាអ្នកពាក់ព័ន្ធទៅនឹងគំរោងវិនិយោគទាំងអស់នោះរួមមាន :

### ៥.៤.១ ស្ថាប័នពាក់ព័ន្ធ

#### ក. មន្ទីរបរិស្ថានខេត្តមណ្ឌលគិរី

ការពិភាក្សាជាមួយលោក ញឹម សុផល អនុប្រធានមន្ទីរបរិស្ថាន ខេត្តមណ្ឌលគិរី ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៩ នៅក្នុងមន្ទីរបរិស្ថាន។ លោកបានមានប្រសាសន៍ថា :

លោកបានដឹងពីវត្តមានគំរោងវិនិយោគនេះតាមរយៈការចូលរួមចុះសិក្សាជាមួយក្រុមការងារខេត្ត និងបណ្តាលមន្ទីពាក់ព័ន្ធនានា។ លោកបានបន្តទៀតថាលោកមានការរីករាយអោយមានការអភិវឌ្ឍន៍ ប៉ុន្តែទន្ទឹមនឹងនេះខាងក្រុមហ៊ុនត្រូវគិតពីហេតុប៉ះពាល់អោយបានច្បាស់លាស់។ ចំពោះផលប៉ះពាល់ទៅលើដីធ្លីរបស់ប្រជាជនវិញលោកបានបញ្ជាក់ថាមានផលប៉ះពាល់តិចតួចបំផុតពីព្រោះទីតាំងគំរោង វិនិយោគនេះស្ថិតនៅក្នុងតំបន់ការពារ ប្រសិនជាមានក៏មានតិចតួចដែរ។ ដោយសារតំបន់នេះធ្លាប់ជាតំបន់ការពារ ការវិនិយោគនេះ និងធ្វើអោយមានផលប៉ះពាល់ដល់សត្វព្រៃខ្លះៗ ដោយសត្វទាំងនោះនឹងធ្វើការបំលាស់ទីទៅតំបន់ស្នូលដែនជំរកសត្វព្រៃភ្នំណាមល្យើរ។ ទោះបីជាមានផលប៉ះពាល់ក៏ពិតមែនប៉ុន្តែបើតាមការថ្លឹងថ្លែងគួរតែមានការវិនិយោគពីព្រោះថាមានផលចំណេញជាង។

ជាចុងក្រោយលោកមានសំណូមពរអោយក្រុមហ៊ុនវិនិយោគចុះមកសំរបសំរួលជាមួយប្រជាជនផ្ទាល់ និងធ្វើការវិនិយោគទៅតាមកិច្ចសន្យាជាមួយរាជរដ្ឋាភិបាលអោយបានត្រឹមត្រូវដើម្បីអោយដំណើរការវិនិយោគទៅដោយរលូន។

**ខ. មន្ទីរកសិកម្មខេត្តមណ្ឌលគីរី**

ការពិភាក្សាជាមួយលោក **អេង ប៊ុនហ៊ាង** ប្រធានមន្ទីរកសិកម្ម ខេត្តមណ្ឌលគីរី ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៩ នៅក្នុងមន្ទីរកសិកម្ម ។ លោកបានមានប្រសាសន៍ថាៈ

លោកបានដឹងពីវត្តមានគំរោងនេះ ដោយខាងមន្ទីរកសិកម្មបានចុះទៅសិក្សាកំណត់ព្រំប្រទល់គំរោង ។ លោកមានការឯកភាពចំពោះគំរោងវិនិយោគនេះព្រោះបើមិនមានការវិនិយោគទេ ដីតំបន់នោះនឹងមានការកាប់រានយកដីធ្វើកម្មសិទ្ធពីសំណាក់ជនឱកាសនិយមមួយចំនួន ។ ស្របគ្នានេះដែរគំរោងវិនិយោគនេះនឹងផ្តល់ផលប្រយោជន៍ជាច្រើនដូចជាផ្តល់ពន្ធជូនរដ្ឋ និងការងារជូនប្រជាជនក្នុងតំបន់ ។ លោកបានបញ្ជាក់ទៀតថា ទីតាំងក្រុមហ៊ុនវិនិយោគនេះមានការពាក់ព័ន្ធដល់ដីស្រែចំការរបស់ប្រជាជនតិចតួចប៉ុណ្ណោះ និងមានការប៉ះពាល់ដល់ធនធានព្រៃឈើខ្លះដែរ ។

ជាចុងក្រោយលោកក៏មានសំណូមពរមួយចំនួនដូចជាៈ

- ក្រុមហ៊ុនគួរផ្តល់អទិភាពដល់ប្រជាជនមូលដ្ឋានដើម្បីអោយចូលបំរើការងារក្នុងក្រុមហ៊ុន ។
- ចំពោះដីស្រែចំការដែលពាក់ព័ន្ធក្នុងតំបន់គំរោងរបស់ប្រជាជន សូមអោយខាងក្រុមហ៊ុនធ្វើការកាត់ចេញអោយបានសមស្រប ។
- សូមខាងក្រុមហ៊ុនវិនិយោគជួយធ្វើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗក្នុងភូមិ-ឃុំ ។

**គ. មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តមណ្ឌលគីរី**

ការពិភាក្សាជាមួយលោកស្រី **បេង រ៉ែន** ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តមណ្ឌលគីរី ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ នៅក្នុងមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ។ លោកស្រីបានមានប្រសាសន៍ថាៈ

មន្ទីរបានដឹងពីវត្តមានរបស់គំរោងវិនិយោគដែលស្ថិតនៅក្នុងដែនជំរកសត្វព្រៃភ្នំណាមលៀវនេះ តែមិនទាន់បានចុះទៅសិក្សាជាក់ស្តែងនៅឡើយទេ ។ លោកស្រីបានបន្តទៀតថា ការវិនិយោគនឹងផ្តល់ផលប្រយោជន៍ជូនរដ្ឋតាមរយៈការបង់ពន្ធ និងផ្តល់ការងារជូនប្រជាជន ។ ទីតាំងគំរោងវិនិយោគនេះអាចមានផលប៉ះពាល់ខ្លះដល់ដីប្រជាជន ពីព្រោះធ្លាប់មានភូមិចាស់នៅក្បែរនោះ ។ ចំពោះបញ្ហាកម្មសិទ្ធិដីធ្លី លោកស្រីបានបញ្ជាក់ថា ស្រុកពេជ្រាដា និងស្រុកអូររាំង មិនទាន់បានចេញប័ណ្ណកម្មសិទ្ធិដីធ្លីនៅឡើយទេ ព្រោះនៅក្នុងតំបន់នេះជាប់ពាក់ព័ន្ធនឹងតំបន់អភិរក្ស និងតំបន់ការពារច្រើន ។ ជាទីបញ្ចប់លោកស្រីសំណូមពរអោយក្រុមហ៊ុនដំណើរការទៅតាមការអនុញ្ញាតរបស់រដ្ឋាភិបាល និងកាត់ដីប្រជាជនកាន់កាប់ស្របច្បាប់ចេញពីក្នុងតំបន់គំរោងវិនិយោគរបស់ក្រុមហ៊ុន ។

Draft

**គ. ខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគិរី**

ការពិភាក្សាជាមួយលោក **កែប កត់** នាយរងខណ្ឌរដ្ឋបាលព្រៃឈើ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ នៅក្នុងខណ្ឌរដ្ឋបាលព្រៃឈើ ។ លោកបានមានប្រសាសន៍ថា:

លោកមិនបានដឹងពីវត្តមានរបស់គំរោងវិនិយោគរបស់ក្រុមហ៊ុននេះទេ ទីតាំងគំរោងវិនិយោគនេះស្ថិតក្នុងដែនជំរកសត្វព្រៃភ្នំណាមលៀរដែលក្រសួងបរិស្ថានជាអ្នកគ្រប់គ្រង ។ ក្នុងតំបន់គំរោងនេះសំបូរទៅដោយព្រៃល្បោះប៉ុន្តែលោកក៏មិនអាចបញ្ជាក់អោយបានច្បាស់ដែរ ដោយសារតែ នៅមិនបានចុះសិក្សានៅឡើយ រីឯសត្វព្រៃមានដូចជា ឈ្លូស និងជ្រូកព្រៃជាដើម ។ ល។ ទីតាំងគំរោងនេះក៏អាចមានផលប៉ះពាល់ទៅលើដីប្រជាជនដែរ និងមានការកាប់ទន្រ្ទានយកដីតិចតួច ។

**ឃ. ផ្នែករដ្ឋបាលព្រៃឈើសែនមនោរម្យ**

ការពិភាក្សាជាមួយលោក **អ៊ុំ វណ្ណសុភៈ** នាយផ្នែករដ្ឋបាលព្រៃឈើសែនមនោរម្យ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៩ នៅក្នុងផ្នែករដ្ឋបាលព្រៃឈើសែនមនោរម្យ ។ លោកបានមានប្រសាសន៍ថា:

លោកបានដឹងពីគំរោងនេះតាមរយៈសាលាខេត្តប៉ុន្តែមិនទាន់ជាផ្លូវការនៅឡើយទេ។ លោកក៏មានការឯកភាពទៅតាមការសំរេចរបស់រដ្ឋាភិបាលដែលសំរេចអោយដីសម្បទានសេដ្ឋកិច្ចទៅក្រុមហ៊ុនវិនិយោគនេះ ។ ចំពោះស្ថានភាពនៅទីតាំងគំរោងនេះលោកមិនបានដឹងអោយបានច្បាស់ទេដោយសារតែពីមុនមកទីតាំងនេះ ស្ថិតនៅក្នុងដែនជំរកសត្វព្រៃភ្នំណាមលៀរដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន ប៉ុន្តែលោកអាចសំគាល់បានថានៅក្នុងតំបន់នេះមិនមានប្រភេទសត្វកំរទេគឺមានតែ ឈ្លូស និងជ្រូកព្រៃជាដើម។ បច្ចុប្បន្ននេះខាងផ្នែករដ្ឋបាលព្រៃឈើបានទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើតាមរយៈការដាក់ស្លាកហាមកាប់ឈើ និងពន្យល់ពីផលប៉ះពាល់ពីការបាត់បង់ព្រៃឈើដល់ប្រជាជនតាមមូលដ្ឋាន។ លោកបានបន្តទៀតថាបច្ចុប្បន្ននេះ ចំពោះដីព្រៃរិចរិលដែលមានតំលៃសេដ្ឋកិច្ចទាបត្រូវបានយកទៅវិនិយោគដើម្បីយកចំណូលជូនរដ្ឋ និងប្រជាជន ។

ជាសំណូមពរ លោកសូមអោយក្រុមហ៊ុនធ្វើដំណើរការវិនិយោគដោយគោរពទៅតាមលក្ខន្តិកៈជាមួយរដ្ឋាភិបាល និង ធ្វើការសហការអោយបានល្អជាមួយអាជ្ញាធរពាក់ព័ន្ធ និងចំពោះឈើដែលក្រុមហ៊ុនឈូសឆាយ រដ្ឋបាលព្រៃឈើសូមអោយក្រុមហ៊ុនប្រមូលទុកដើម្បីអោយរដ្ឋបាលព្រៃឈើវាយតំលៃហើយបង់ពន្ធជូនរដ្ឋ។

**ង. ដែនជំរកសត្វព្រៃភ្នំណាមលៀរ**

ការពិភាក្សាជាមួយលោក **ហួត ពិសិដ្ឋ** នាយកដែនជំរកសត្វព្រៃភ្នំណាមលៀរ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ នៅក្នុងទីស្នាក់ដែនជំរកសត្វព្រៃភ្នំណាមលៀរ ។ លោកមានប្រសាសន៍ថា :

លោកបានដឹងពីវត្តមានគំរោង តាមរយៈឯកសារដែលមានស្រាប់ពីនាយកដែនជំរកសត្វព្រៃ ចាស់។ លោកគាំទ្រទៅលើការអភិវឌ្ឍន៍នេះ ពីព្រោះវាជាគោលការណ៍របស់រដ្ឋាភិបាល ហើយម្យ៉ាងទៀតខាងក្រសួងក៏បានចុះមកសិក្សាពីទីតាំងមុនសំរេចអោយក្រុមហ៊ុនអភិវឌ្ឍន៍។ ចំពោះផលប៉ះពាល់លោកមិនអាចសន្និដ្ឋានបាន ពីព្រោះលោកទើបតែមកកាន់តំណែងថ្មី។ លោកបន្តទៀតថា ចំណែកផលប្រយោជន៍ក្រុមហ៊ុនផ្តល់អោយប្រជាជននៅក្នុងមូលដ្ឋាននោះគឺ ជួយឱ្យធ្វើជាកម្មករក្នុងក្រុមហ៊ុន ដើម្បីឱ្យជីវភាពធូរធារ និងបង្កើតហេដ្ឋារចនាសម្ព័ន្ធថ្មីទៀត។

ជាសំណូមពរលោកនាយកដែន សូមឱ្យក្រុមហ៊ុនមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយដែន និងផ្តត់ផ្តង់ដល់ដែន ដើម្បីធ្វើការអភិរក្សបរិស្ថានជុំវិញដែន។

## ៥.៤.២ អាជ្ញាធរមូលដ្ឋាន និងប្រជាជនមូលដ្ឋាន

### ក.អាជ្ញាធរខេត្តមណ្ឌលគិរី

ក្រុមសិក្សាស្រាវជ្រាវបានជួបពិភាក្សាជាមួយឯកឧត្តម **ញ៉ាំ ភាំង** ចាន់ អភិបាលរងខេត្តមណ្ឌលគិរី នាថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៩ នៅក្នុងសាលាខេត្តមណ្ឌលគិរី។ ឯកឧត្តមបានមានប្រសាសន៍ថា :

ឯកឧត្តមបានដឹងពីវត្តមានគំរោងវិនិយោគរបស់ក្រុមហ៊ុននេះ។ ឯកឧត្តមក៏មានការឯកភាពចំពោះវត្តមានរបស់គំរោងនេះផងដែរ ពីព្រោះថាគំរោងវិនិយោគនេះនឹងផ្តល់ប្រយោជន៍អោយប្រជាជនមានការងារធ្វើ និងផ្តល់ចំណូលជូនរដ្ឋ។ ឯកឧត្តមបានបន្តទៀតថា ដីនៅតំបន់នេះគួរតែធ្វើការអភិវឌ្ឍន៍ប្រសើរជាងទុកដីព្រៃដែលមានតំលៃសេដ្ឋកិច្ចតិចតួចព្រោះគំរោងនឹងផ្តល់ផលប្រយោជន៍ជូនប្រជាជន និងរដ្ឋ។ ប៉ុន្តែគំរោងវិនិយោគនេះមានផលប៉ះពាល់ទៅលើដីព្រៃនៅក្នុងដែនជំរកសត្វព្រៃភ្នំណាមលៀរ។

Draft

ជាសំណូមពរឯកឧត្តម សូមអោយក្រុមហ៊ុនជ្រើសរើសប្រជាជននៅក្នុងតំបន់បំរើការក្នុងក្រុមហ៊ុន និងប្រសិនជាការវិនិយោគនេះមានផលប៉ះពាល់ដល់ដីធ្លីប្រជាជន សូមអោយក្រុមហ៊ុនរកដំណោះស្រាយសមស្របជូនប្រជាជនដោយជៀសវាងនូវទំនាស់។

### ខ. អាជ្ញាធរស្រុកពេជ្រាដា

ការពិភាក្សាជាមួយលោក **មើល សឿន** អភិបាលស្រុកពេជ្រាដា ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៩ នៅសាលាស្រុកពេជ្រាដា។ លោកបានមានប្រសាសន៍ថា :

លោកបានដឹងពីការស្នើរសុំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនវិនិយោគនេះនៅឆ្នាំ២០០៨។ ក្រុមហ៊ុនវិនិយោគនេះបានទទួលដីសម្បទានសេដ្ឋកិច្ចដែលអនុញ្ញាតដោយព្រះរាជក្រឹត។ លោកមានការឯកភាពទៅនឹងការវិនិយោគរបស់ក្រុមហ៊ុននេះដោយសារតែ ក្រុមហ៊ុននឹងជួយលើកកំពស់សេដ្ឋកិច្ចជាតិ ជួយអោយប្រជាជនមានការងារធ្វើ និងអភិវឌ្ឍន៍ភូមិ-ឃុំ ដូចជា ធ្វើផ្លូវ សាលារៀន និងសេវាផ្សេងៗ និងអាចជួយអោយដីដែលគ្មានគំរបព្រៃមានគំរបព្រៃឡើងវិញ ប៉ុន្តែ

សុំអោយក្រុមហ៊ុនធ្វើការសិក្សាអោយបានច្បាស់លាស់លើដីប្រជាជន ដីព្រៃខ្លោច ព្រៃតំណម និងមានទុកដីសម្បទានសង្គមកិច្ចជូនប្រជាជន។ បច្ចុប្បន្ននេះខាងស្រុកទទួលស្គាល់ដីប្រជាជនដែលបានតាំងទីលំនៅតាំងពីឆ្នាំ ១៩៧៩ មានដូចជាដីចំការ និងដីលំនៅដ្ឋាន។ ចំពោះបញ្ហាសត្វព្រៃលោកបានមានប្រសាសន៍ថា ប្រភេទសត្វព្រៃមានដូចជា សត្វឈ្លូស និងជ្រូកព្រៃ តិចតួចព្រោះសត្វភាគច្រើនបានផ្លាស់ទីទៅរស់នៅទន្លេស្រែពកដោយសារតែប្រជាជន ធ្វើចំការ ដងជ័រ និងការឈូសឆាយរបស់ក្រុមហ៊ុនវិនិយោគនានា។

ជាសំណូមពរ លោកសូមអោយក្រុមហ៊ុនគ្រប់គ្រងកាកសំណល់អោយបានល្អកុំឱ្យប៉ះពាល់ដល់ប្រជាជននៅពេលបង្កើតរោងចក្រ និងចូលរួមសហការអោយបានល្អជាមួយអាជ្ញាធរពាក់ព័ន្ធ និងប្រជាពលរដ្ឋ។ លោកសូមអោយក្រុមហ៊ុនរក្សាព្រៃតំណម ព្រៃខ្លោច និងសូមអោយក្រុមហ៊ុនទទួលយកប្រជាជនក្នុងភូមិអោយចូលធ្វើជាកម្មករអោយអស់ពីលទ្ធភាពសិនមុននឹងទទួលយកកម្មករពីស្រុកដទៃ។

## គ. អាជ្ញាធរឃុំប៊ូស្រា

ការពិភាក្សាជាមួយលោក **គេង ញ៉ាក់** មេឃុំប៊ូស្រា ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៩ នៅសាលាឃុំប៊ូស្រា។ លោកបានមានប្រសាសន៍ថា :

លោកទើបតែដឹងពីគំរោងរបស់ក្រុមហ៊ុនវិនិយោគនេះនៅពេលចុះធ្វើការកំនត់ទីតាំង។ លោកមានការឯកភាពចំពោះការវិនិយោគនេះដោយសារការវិនិយោគនេះនឹងបង្កើនការងារអោយប្រជាជន និងជួយកសាងនូវហេដ្ឋារចនា សម្ព័ន្ធផ្សេងៗក្នុងឃុំ ប៉ុន្តែលោកសូមអោយខាងក្រុមហ៊ុនវិនិយោគ ធ្វើការសិក្សាពីផលប៉ះពាល់បរិស្ថានអោយបានច្បាស់លាស់ ជាពិសេសគឺផលប៉ះពាល់ដល់ដីកម្មសិទ្ធិដែលជាស្រែចំការចាស់របស់ប្រជាជន។ លោកបានបន្តទៀតថាបើតាមលោកបានដឹងនៅក្នុងទីតាំងគំរោងនេះមានប្រជាជនប្រមាណជា៨២គ្រួសារដែលរស់នៅដែលមានប្រភពមកពីភូមិពូលុក និងមិនសូវសំបូរព្រៃឈើទេ រីឯសត្វព្រៃមានសំបូរ ជ្រូកព្រៃ និងផ្លុងតូច។ ជាទីបញ្ចប់លោកសំណូមពរអោយក្រុមហ៊ុនវិនិយោគសិក្សាពីផលប៉ះពាល់បរិស្ថានក៏ដូចជាបញ្ហាប៉ះពាល់ដីចំការប្រជាជនឱ្យបានច្បាស់លាស់។

## ឃ. អាជ្ញាធរភូមិពូលុ

ការពិភាក្សាជាមួយលោក **យ៉ង់ ផល** មេភូមិពូលុ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៩ នៅភូមិពូលុ។ លោកបានមានប្រសាសន៍ថា :

លោកមិនបានដឹងពីវត្តមាននៃគំរោងវិនិយោគរបស់ក្រុមហ៊ុនសេដ្ឋីកុលានេះទេ។ គំរោងវិនិយោគនេះមានការប៉ះពាល់ដល់ដីស្រែ ចំការ ដីបំរុងទុក ដីព្រៃតំណម ៤កន្លែង និងដីព្រៃខ្លោច ២កន្លែង បន្ទាប់មកលោកបានបន្តទៀតថា លោកមានការឯកភាពចំពោះគំរោងវិនិយោគនេះ ប្រសិនបើខាងក្រុមហ៊ុនវិនិយោគធ្វើការដោះស្រាយបញ្ហាដីធ្លីប្រជាជន

អោយបានសមស្របដូចជា កាត់ដីដែលប៉ះពាល់ចេញ។ ចំពោះការដោះស្រាយទៅលើការប៉ះពាល់លើដីធ្លីរបស់ប្រជាជន លោកយល់ថាក្រុមហ៊ុនត្រូវធ្វើការពិភាក្សាជាមួយប្រជាជនផ្ទាល់តែម្តង ដើម្បីរកដំណោះស្រាយដូចជា កាត់ដីចេញ រឺក៏សហការដាំបង្ខាស់ជាមួយប្រជាជន។ សំរាប់ផលប៉ះពាល់លើព្រៃតំណម និងព្រៃខ្មោចក្រុមហ៊ុនវិនិយោគត្រូវពិភាក្សាជាមួយប្រជាជន និងចាស់ទុំក្នុងភូមិដើម្បីរកដំណោះស្រាយដូចជា ត្រូវសែនព្រេនជាដើម។ លោកក៏មានសំណូមពរអោយក្រុមហ៊ុនជ្រើសរើសកំលាំងពលកម្មក្នុងតំបន់អោយអស់ពីលទ្ធភាពសិនមុននឹងរើសកំលាំងពលកម្មពីខាងក្រៅ និងលោកសូមអោយក្រុមហ៊ុនវិនិយោគកាត់ចេញនូវផ្ទៃដីដែលពាក់ពន្ធ័របស់ប្រជាជន។

### ឃ.១ ប្រជាជនភូមិពូលុ

ការពិភាក្សាជាមួយប្រជាជនភូមិពូលុត្រូវបានធ្វើឡើងកាលពីថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៩ នៅភូមិពូលុ។ ឆ្លងតាមការពិភាក្សាជាមួយប្រជាជនបានអោយដឹងថាទីតាំងគំរោងវិនិយោគនេះមានការប៉ះពាល់ដល់ដីស្រែ-ចំការរបស់ប្រជាជនច្រើន។ បន្ទាប់មកប្រជាជនបានមានយោបល់ជារួមមួយគឺ ប្រជាជនមានការឯកភាពចំពោះក្រុមហ៊ុនវិនិយោគនេះប្រសិនបើក្រុមហ៊ុនធ្វើការកាត់នៅផ្ទៃដីប៉ះពាល់របស់ប្រជាជនចេញ។ ប្រជាជនក៏មានសំណូមពរមួយចំនួនដូចជា សូមអោយក្រុមហ៊ុនកាត់ដីដែលពាក់ព័ន្ធរបស់ប្រជាជនចេញជាមុនសិនមុននឹងធ្វើការវិនិយោគ និងសូមអោយក្រុមហ៊ុនចុះមកកាត់ដីដែលមានការពាក់ព័ន្ធជាមួយប្រជាជនផ្ទាល់ និងសូមអោយក្រុមហ៊ុនទទួលយកប្រជាជនក្នុងមូលដ្ឋានធ្វើជាកម្មករអោយអស់ពីលទ្ធភាព។

### ង. អាជ្ញាធរភូមិឡាំមេះ

ការពិភាក្សាជាមួយលោក **កុយ សុម៉ាលី** មេភូមិឡាំមេះ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៩ នៅភូមិឡាំមេះ។ លោកបានមានប្រសាសន៍ថា :

លោកទើបតែបានដឹងពីគំរោងវិនិយោគរបស់ក្រុមហ៊ុននេះក្នុងពេលថ្មីៗនេះទេនៅពេលធ្វើការចុះកំនត់ទីតាំង។ លោកមានការពេញចិត្តអោយមានក្រុមហ៊ុនចូលមកធ្វើការវិនិយោគក្នុងតំបន់ ដោយសារគំរោងវិនិយោគនេះនឹងជួយលើកស្ទួយកំរិតជីវភាពប្រជាជនក្នុងមូលដ្ឋាន។ ជាមួយគ្នានោះដែរ លោកក៏បានលើកឡើងពីបញ្ហាប៉ះពាល់ដោយគំរោងវិនិយោគដែរដូចជា ប៉ះពាល់ដល់ដីស្រែចំការ ព្រៃតម និងព្រៃខ្មោច របស់ប្រជាជន។ ជាចុងក្រោយលោកសំណូមពរអោយក្រុមហ៊ុនធ្វើការសហការណ៍ដើម្បីដាំកៅស៊ូជាលក្ខណៈគ្រួសារជាមួយប្រជាជន និងដោះស្រាយបញ្ហាដីធ្លីជាមួយប្រជាជនដោយធ្វើការដោះដូរ រឺទិញពីប្រជាជនក្នុងតំលៃសមរម្យ និងសូមអោយទទួលយកប្រជាជនក្នុងភូមិធ្វើជាកម្មករព្រមទាំងជួយធ្វើការកសាងហេដ្ឋារចនាសម្ព័ន្ធក្នុងភូមិ។

Draft

### ង.១ ប្រជាជនភូមិឡាំមេះ

ការពិភាក្សាជាមួយប្រជាជនភូមិឡាំមេះត្រូវបានធ្វើឡើងកាលពីថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៩ នៅភូមិឡាំមេះ។ ក្រោយពីការពិភាក្សាជាមួយប្រជាជនបានអោយដឹងថាប្រជាជននឹងយល់ព្រមចំពោះការវិនិយោគនេះ ប្រសិនបើក្រុមហ៊ុនធ្វើការដោះស្រាយបញ្ហាដីធ្លីជាមួយប្រជាជនក្នុងភូមិអោយបានសមស្រប ពីព្រោះនៅទីតាំងគំរោងវិនិយោគនេះក៏មានប៉ះពាល់ដីរបស់ប្រជាជនភូមិឡាំមេះដែរ។ ចំពោះដំណោះស្រាយពីបញ្ហាដីធ្លីពាក់ព័ន្ធនេះមានប្រជាជន មួយចំនួនមានបំណងចង់លក់ដីដែលប៉ះពាល់អោយខាងក្រុមហ៊ុនវិនិយោគ មានមួយចំនួនទៀតមានបំណងចង់ដាំបង្ហាស់ជាមួយក្រុមហ៊ុនវិនិយោគ និងមានមួយចំនួនទៀតក៏មិនព្រមលក់ដីអោយក្រុមហ៊ុនវិនិយោគទេ។ ជាចុងក្រោយប្រជាជនសូមអោយក្រុមហ៊ុនវិនិយោគធ្វើការវាស់វែងដីធ្លីពាក់ព័ន្ធរបស់ប្រជាជនអោយបានត្រឹមត្រូវ មុននឹងធ្វើការឈូសឆាយអនុវត្តគំរោងវិនិយោគ និងសូមអោយក្រុមហ៊ុនវិនិយោគរក្សាដីរបស់ប្រជាជនដើម្បីអោយប្រជាជនប្រកបរបបចញ្ចឹមជីវិត។

### ច. អាជ្ញាធរភូមិប៊ូស្រា

ការពិភាក្សាជាមួយលោក **ម្រួប កុំជា** មេភូមិប៊ូស្រា ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៩ នៅភូមិប៊ូស្រា។ លោកបានមានប្រសាសន៍ថា :

លោកមិនបានដឹងពីវត្តមានគំរោងវិនិយោគរបស់ក្រុមហ៊ុននេះទេ និងក្រោយពីការពិនិត្យទៅលើទីតាំងរួចលោកបានបញ្ជាក់ថាទីតាំងរបស់គំរោងវិនិយោគនេះមានការប៉ះពាល់ដល់ ដីស្រែ-ចំការ ដីចំការវិលជុំរបស់ប្រជាជនភូមិប៊ូស្រាចំនួន ១២ គ្រួសារ ព្រៃខ្លោច ១ កន្លែង និងព្រៃតំណម ១ កន្លែងនៅខាងកើតអូររ៉េត (ទាំងព្រៃខ្លោច និងព្រៃតំណមមានប្រហែលជា ៤ហត)។ ដំណោះស្រាយចំពោះការប៉ះពាល់ដល់ដីធ្លីរបស់ប្រជាជនលោកយល់ឃើញថាក្រុមហ៊ុនវិនិយោគត្រូវសងជាដីធ្លីជូនប្រជាជនវិញ រឺក៏ទិញដីពីប្រជាជនដែលមានបំណងចង់លក់ និងធ្វើការសហការណ៍ជាមួយប្រជាជនដើម្បីដាំកៅស៊ូសំរាប់ប្រជាជនដែលមានបំណងដាំបង្ហាស់ជាមួយក្រុមហ៊ុន។ សំរាប់ដំណោះស្រាយទៅលើព្រៃតំណម និងដីព្រៃខ្លោចក្រុមហ៊ុនត្រូវតែរក្សាទុកជូនប្រជាជនក្នុងភូមិវិញព្រោះដីព្រៃទាំងនោះមានប្រយោជន៍ដល់ទំនាមទំលាប់ប្រពៃណី និងសត្វព្រៃក្នុងតំបន់។ បន្ទាប់មកលោកបានបន្តទៀតថា លោកមិនអាចសំរេចចិត្តឯកភាពរឺមិនឯកភាពទៅលើគំរោងវិនិយោគនេះបានទេ អ្វីទាំងអស់គឺអាស្រ័យលើប្រជាជនដែលរស់នៅក្នុងភូមិទាំងមូល។

ជាទីបញ្ចប់លោកមានសំណូមពរអោយក្រុមហ៊ុនវិនិយោគចុះទៅដល់ទីតាំងដែលមានការប៉ះពាល់ដល់ដីធ្លីរបស់ប្រជាជនផ្ទាល់ហើយធ្វើការវាស់វែង និងកាត់ចេញនូវដីប៉ះពាល់ទាំងនោះចេញអោយបានត្រឹមត្រូវ (ដោយមានការធ្វើជាសំបុត្រធានាពីការកាត់ចេញនូវដីប៉ះពាល់)។

Draft

**ច.១ ប្រជាជនភូមិប៊ូស្រា**

ការពិភាក្សាជាមួយប្រជាជនភូមិប៊ូស្រាត្រូវបានធ្វើឡើងកាលពីថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៩ នៅភូមិប៊ូស្រា។ ប្រជាជនភូមិប៊ូស្រាមានយោបល់ថា មុននឹងក្រុមហ៊ុនធ្វើការឈូសឆាយត្រូវធ្វើការសិក្សាអោយបានច្បាស់លាស់ជាមួយប្រជាជនដែលមានដីធ្លីប៉ះពាល់ដល់ទីតាំងគំរោងផ្ទាល់។ ប្រជាជនក្នុងភូមិបានបន្តទៀតថាទោះបីជាទីតាំងវិនិយោគនេះមានការប៉ះពាល់ដល់ប្រជាជនក្នុងភូមិតិចតួច ក៏ប្រជាជនសំណូមពរអោយក្រុមហ៊ុនធ្វើការសិក្សាជាមួយភូមិផ្សេងៗផងដែរ ដើម្បីកុំអោយមានបញ្ហាទៅថ្ងៃក្រោយ និងសូមអោយក្រុមហ៊ុនវិនិយោគជ្រើសរើសប្រជាជនក្នុងភូមិធ្វើការអោយក្រុមហ៊ុនអោយបានច្រើន។

**ឆ. អាជ្ញាធរភូមិពូទឹត**

ការពិភាក្សាជាមួយលោក **ស្រេង អៀច** មេភូមិពូទឹត ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩ នៅភូមិពូទឹត។ លោកបានមានប្រសាសន៍ថា :

លោកមិនបានដឹងពីវត្តមានគំរោងវិនិយោគរបស់ក្រុមហ៊ុននេះទេ។ បន្ទាប់ពីបានដឹងពីទីតាំងរបស់គំរោងវិនិយោគនេះ លោកបានមានប្រសាសន៍ថាទីតាំងនេះមានការប៉ះពាល់ដល់ដីចំការចាស់របស់ប្រជាជនភូមិពូទឹតប្រមាណជា ២០គ្រួសារនៅតំបន់ចាប់ពីអូរកាឡើងទៅ ម្យ៉ាងទៀតទីតាំងនេះក៏មានការប៉ះពាល់ ដល់ដីព្រៃខ្មោច និងព្រៃតំណមរបស់ប្រជាជនដែរ។ ចំពោះដំណោះស្រាយពីបញ្ហាដីធ្លីវិញលោកមានគំនិតថាខាងក្រុមហ៊ុនវិនិយោគត្រូវធ្វើការពិភាក្សាជាមួយប្រជាជនផ្ទាល់។ ជាសំណូមពរលោកសូមអោយថ្នាក់លើជួយចុះមកធ្វើការចរចារពន្យល់ និងសម្រុះសម្រួលដើម្បីអោយប្រជាជនបានយល់ និងសហការណ៍ជាមួយក្រុមហ៊ុនវិនិយោគ។

**បញ្ជាក់ :** *ប្រជាជនភូមិពូទឹតមិនព្រមចូលរួមផ្តល់យោបល់ និងផ្តល់ទិន្នន័យស្តីពីដីធ្លីដែលពាក់ព័ន្ធនឹងគំរោងដោយសារតែប្រជាជនធ្លាប់មានទំនាស់និងក្រុមហ៊ុនអភិវឌ្ឍន៍កន្លងមក។*

**ជ. អាជ្ញាធរភូមិពូរាំង**

ការពិភាក្សាជាមួយលោក **មឿង ឃ្មីរ** មេភូមិពូរាំង ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩ នៅភូមិពូរាំង។ លោកបានមានប្រសាសន៍ថា :

លោកមិនបានដឹងពីវត្តមានរបស់ក្រុមហ៊ុនវិនិយោគនេះទេ។ លោកបានបន្តទៀតថាទីតាំងវិនិយោគនេះមានការប៉ះពាល់ដល់ដីចំការរបស់ប្រជាជនភូមិពូរាំងចំនួន ១៩គ្រួសារ និងមានព្រៃតំណម ចំនួន ៣កន្លែង និងព្រៃខ្មោច ២កន្លែង ប៉ុន្តែលោកមិនអាចកំណត់ពីទំហំបានទេ។ បើតាមគំនិតលោកប្រជាជនភាគច្រើនមានបំណងដោះស្រាយបញ្ហាដីធ្លីពាក់ព័ន្ធដោយធ្វើការដាំបង្គោលជាមួយក្រុមហ៊ុន និងសំរាប់បញ្ហាព្រៃតំណម និងព្រៃខ្មោច គឺត្រូវទុកដីព្រៃទាំងនោះអោយនៅ

ដដែល( ហាមមិនអោយមានការកាប់រានទេ)។ លោកមានការឯកភាពចំពោះគំរោងវិនិយោគ ប្រសិនបើក្រុមហ៊ុនធ្វើការដោះស្រាយបញ្ហាដីធ្លីពាក់ព័ន្ធ និងដីព្រៃតំណម និងព្រៃខ្មោច របស់ប្រជាជនអោយបានសមស្រប។

ជាចុងក្រោយលោកមានសំណូមពរអោយខាងក្រុមហ៊ុនធ្វើការដោះស្រាយរាល់ការប៉ះពាល់ទាំងឡាយ (ដីធ្លីរបស់ប្រជាជន ព្រៃតំណម ព្រៃខ្មោច) ទៅតាមការស្នើសុំរបស់ប្រជាជន និងសូមអោយខាងក្រុមហ៊ុនវិនិយោគជ្រើសរើសយកប្រជាជនក្នុងភូមិទៅបំរើការក្នុងក្រុមហ៊ុនអោយបានច្រើន។

### ជ.១ ប្រជាជនភូមិពូរាំង

ការពិភាក្សាជាមួយប្រជាជនភូមិពូរាំងត្រូវបានធ្វើឡើងកាលពីថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩ នៅភូមិពូរាំង។ ឆ្លងតាមការពិភាក្សាជាមួយប្រជាជនក្នុងភូមិបានអោយដឹងថាទីតាំងគំរោងវិនិយោគនេះមានការប៉ះពាល់ដល់ដីធ្លីរបស់ប្រជាជនក្នុងភូមិពូរាំងច្រើន ប៉ុន្តែប្រជាជននៅតែមានការឯកភាពទៅលើគំរោងវិនិយោគនេះប្រសិនបើខាងក្រុមហ៊ុនធ្វើការដាំបង្ហាស់ជាមួយប្រជាជន។ ប្រជាជនអនុញ្ញាតអោយក្រុមហ៊ុនធ្វើការឈូសឆាយដីរបស់ប្រជាជនពាក់កណ្តាល និងទុកដីពាក់កណ្តាលសំរាប់ប្រជាជនធ្វើការដាំបង្ហាស់ជាមួយក្រុមហ៊ុន ប៉ុន្តែចំពោះដីស្រែវិញប្រជាជនសូមរក្សាទុកដើម្បីប្រកបរបបចិញ្ចឹមជីវិត។ មុននឹងបញ្ចប់កិច្ចពិភាក្សាប្រជាជនមានសំណូមពរអោយក្រុមហ៊ុនវិនិយោគធ្វើការទំនាក់ទំនងជាមួយប្រជាជនមុនសិន និងសូមអោយក្រុមហ៊ុនវិនិយោគជ្រើសរើសប្រជាជនក្នុងភូមិធ្វើបុគ្គលិកអោយអស់ពីលទ្ធភាព។

### ឈ. អាជ្ញាធរភូមិពូចារ

ការពិភាក្សាជាមួយលោក **ស្រេត ឡាយ** មេភូមិពូចារ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៩ នៅភូមិពូចារ។ លោកបានមានប្រសាសន៍ថា :

លោកមិនបានដឹងពីវត្តមានគំរោងវិនិយោគរបស់ក្រុមហ៊ុននេះពីមុនមកទេ។ លោកបានស្រង់បានប្រជាជនចំនួន ៣៩គ្រួសារ ដែលមានដីពាក់ព័ន្ធនៅក្នុងទីតាំងគំរោងវិនិយោគនេះ ប៉ុន្តែលោកបានបញ្ជាក់ទៀតថាជាក់ស្តែងអាចនៅមានប្រជាជនដែលមានដីពាក់ព័ន្ធច្រើនជាងនេះទៀត។ នៅទីតាំងនេះមានដីព្រៃខ្មោចរបស់ប្រជាជនភូមិពូទឹត ប៉ុន្តែស្ថិតក្រោមការគ្រប់គ្រងរបស់មេភូមិពូចារ (តំបន់ក្លែរអី)។ ចំពោះដំណោះស្រាយដីធ្លីពាក់ព័ន្ធរបស់ប្រជាជនគឺស្ថិតនៅលើប្រជាជនរីឯព្រៃតំណម និងព្រៃខ្មោចត្រូវតែទុកអោយប្រជាជន។ លោកបានបន្តទៀតថាការសំរេចចិត្តឯកភាពគឺអាស្រ័យទៅលើប្រជាជនប្រសិនបើប្រជាជនឯកភាពលោកក៏មានការឯកភាពទៅតាមប្រជាជនដែរ។

ជាទីបញ្ចប់លោកមានសំណូមពរមួយចំនួនដូចជា សូមអោយក្រុមហ៊ុនសហការណ៍ជាមួយប្រជាជនមូលដ្ឋានជាមុនដើម្បីកុំអោយមានបញ្ហាដីធ្លីជាមួយប្រជាជន។ លោកសូមអោយក្រុមហ៊ុនត្រូវធ្វើការសម្របសម្រួលជាមួយនឹងសំណូមពរ



Draft

ប្រជាជនអោយបានសមស្រប និងកាត់ដីស្រែរបស់ប្រជាជនចេញមុនពេលធ្វើការឈូសឆាយ។ សូមអោយក្រុមហ៊ុនជ្រើសរើសកម្មករនៅក្នុងស្រុកធ្វើការ បំរើក្នុងក្រុមហ៊ុនអោយអស់ពីលទ្ធភាព។

### ឈ.១ ប្រជាជនភូមិពូចារ

ការពិភាក្សាជាមួយប្រជាជនភូមិពូចារត្រូវបានធ្វើឡើងកាលពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៩ នៅភូមិពូចារ។ ប្រជាជនភូមិពូចារក៏មិនខុសពីប្រជាជនភូមិដទៃទៀតដែរ ពួកគាត់នឹងមានការឯកភាពចំពោះគំរោងវិនិយោគនេះប្រសិនបើខាង ក្រុមហ៊ុនវិនិយោគកាត់នូវដីពាក់ព័ន្ធរបស់ប្រជាជនចេញ និងនៅពេលធ្វើការកាត់ដីពាក់ព័ន្ធចេញប្រជាជនក្នុងភូមិសំណូមពរអោយក្រុមហ៊ុនជៀសវាងការអនុវត្តន៍គំរោងស្បែកខ្លា ពីព្រោះបើដីក្រុមហ៊ុននៅជុំវិញដីប្រជាជននោះប្រជាជនពិបាកក្នុងការធ្វើចំការវិលជុំរបស់គាត់តាមរយៈការដុត និងអាចមានការប៉ះពាល់ដល់ក្រុមហ៊ុនដែរដូចជា សត្វចិញ្ចឹមរបស់ប្រជាជនបំផ្លាញកូនកៅស៊ូរបស់ក្រុមហ៊ុនជាដើម។ ដូចនេះខាងក្រុមហ៊ុនត្រូវចុះធ្វើការសិក្សា និងផ្ទៀងផ្ទាត់បញ្ហាដីធ្លីរបស់ប្រជាជនអោយបានច្បាស់លាស់ និងត្រូវមានការឯកភាពពីម្ចាស់ដី និងត្រូវធ្វើកិច្ចសន្យាផង។ មានប្រជាជនមួយចំនួនមានបំណងធ្វើការដាំបង្វាស់ជាមួយក្រុមហ៊ុនដោយអោយក្រុមហ៊ុនជួយធ្វើការឈូសឆាយ ផ្តល់ជាពូជ និងផ្តល់ជាបច្ចេកទេស និងធ្វើការចុះកុងត្រារយៈពេល ១០ឆ្នាំ។

### ឌ. អាជ្ញាធរស្រុកអូររាំង

ការពិភាក្សាជាមួយលោក **ខាំ ដារ៉ា និង ស្រែម កែម** អភិបាលរងស្រុកអូររាំង ត្រូវបានធ្វើឡើងកាលពីថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩ នៅសាលាស្រុកអូររាំង។ លោកបានមានប្រសាសន៍ថា :

លោកបានដឹងពីវត្តមាននៃគំរោងវិនិយោគរបស់ក្រុមហ៊ុននេះ នាថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០០៩ តាមរយៈមន្ទីរបរិស្ថានខេត្តមណ្ឌលគីរី។ លោកមិនមានការជំទាស់អ្វីទេលើគំរោងវិនិយោគនេះពីព្រោះគំរោងវិនិយោគនឹងផ្តល់ផលប្រយោជន៍ជាច្រើនដល់ប្រទេសជាតិ។ ចំពោះការប៉ះពាល់ដល់ដីធ្លីរបស់ប្រជាជនលោកមានយោលបល់ថាអោយក្រុមការងារចុះសិក្សាដល់ថ្នាក់ឃុំដើម្បីអោយទទួលបានព័ត៌មានកាន់តែច្បាស់។ លោកមានគំនិតថាដើម្បី បញ្ចៀសទំនាស់ដីធ្លីរវាងក្រុមហ៊ុន និងប្រជាជនខាងក្រុមហ៊ុនត្រូវកសាងក្រុមការងារដែលមានមន្ត្រីជំនាញពាក់ព័ន្ធ អាជ្ញាធរដែនដីចូលរួមចុះទៅសិក្សាដល់ទីតាំងផ្ទាល់ជាមួយប្រជាជននៅទីតាំងនោះ ដើម្បីកំណត់អោយបានច្បាស់នូវផលប៉ះពាល់នានា។ ជាសំណូមពរប្រសិនបើការសិក្សាទៅហើយឃើញថាមានការប៉ះពាល់ដល់ប្រជាជនស្រុកអូររាំង លោកសូមអោយខាងក្រុមហ៊ុនមានគោលការណ៍ដោះស្រាយអោយបានសមស្រប។

Draft

## ប. អាជ្ញាធរឃុំដាក់ដាំ

ការពិភាក្សាជាមួយលោក **សម វាន្នី** មេឃុំដាក់ដាំ ត្រូវបានធ្វើឡើង កាលពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៩ នៅឃុំដាក់ដាំ ។ លោកបានមានប្រសាសន៍ថា :

លោកបានដឹងពីវត្តមាននៃគំរោងវិនិយោគរបស់ក្រុមហ៊ុននេះតាមរយៈការចូលរួមប្រជុំជាមួយក្រុមហ៊ុននៅមន្ទីរដែនដី និងមន្ទីរបរិស្ថានខេត្តមណ្ឌលគិរី ។ លោកមានការឯកភាពលើគំរោងអភិវឌ្ឍន៍ដោយសារគំរោងវិនិយោគនេះនឹងផ្តល់ផលប្រយោជន៍ដល់ប្រជាជនដូចជា បង្កើតនូវការងារដល់ប្រជាជនមូលដ្ឋាន ប៉ុន្តែលោកសូមអោយធ្វើការកាត់ចេញនូវផ្ទៃដីដែលប៉ះពាល់របស់ប្រជាជន ។ លោកបានបញ្ជាក់ថាទីតាំងគំរោងវិនិយោគនេះមិនមានការប៉ះពាល់ដល់ដីធ្លីប្រជាជនឃុំដាក់ដាំទេ ប៉ុន្តែមានការប៉ះពាល់ដល់ដីស្រែចំការរបស់ប្រជាជននៅឃុំប៊ូស្រាដោយសារពួកគាត់បានមកធ្វើចំការនៅត្រង់តំបន់នេះដែលស្ថិតនៅក្នុងឃុំដាក់ដាំ ។ មានប្រជាជនដែលរស់នៅក្នុងឃុំដាក់ដាំប្រមាណ ១២គ្រួសារបានសង់ផ្ទះក្បែរតំបន់គំរោងនៅឃុំដាក់ដាំ និងមានផ្ទះទុកចោលមួយចំនួនទៀត (សង់ផ្ទះទុកចោលដើម្បីចាំដី) ។ ចំពោះធនធានព្រៃឈើ និងសត្វព្រៃមិនមានការប៉ះពាល់ជាធំដុំជាដុំកំភួននោះទេ ។

ជាចុងក្រោយលោកសូមអោយក្រុមហ៊ុនវិនិយោគមុននឹងធ្វើការវិនិយោគសូមអោយពិភាក្សាជាមួយអាជ្ញាធរ និងចាស់ព្រឹទ្ធាចារ្យ និងប្រជាជនមូលដ្ឋាន និងសូមអោយក្រុមហ៊ុនវិនិយោគធ្វើការរក្សាទុកនូវផ្ទៃដីស្រែ-ចំការ ដីព្រៃតំណមដីព្រៃខ្មោច និងដីព្រៃបំរុងទុក ទាំងឡាយណាដែលក្រុមហ៊ុនបានសិក្សាទៅឃើញថាមានការប៉ះពាល់ ។

Draft

**តារាង ៥.១ : ការសង្ខេបពីមតិយោបល់របស់អាជ្ញាធរពាក់ព័ន្ធ**

| **អ្នកពាក់ព័ន្ធ** | **មតិយោបល់** | **សំណូមពរ** |
|---|---|---|
| **ក. ស្ថាប័ន និងមន្ទីរជំនាញពាក់ព័ន្ធ** | | |
| - លោក **ញ៉ឹម សុផល** អនុប្រធានមន្ទីរបរិស្ថានខេត្តមណ្ឌលគិរី | លោកបានដឹងពីវត្តមានគំរោងវិនិយោគនេះ និង ឯកភាព ប៉ុន្តែខាងក្រុមហ៊ុន ត្រូវគិតពីហេតុប៉ះពាល់ អោយបានច្បាស់លាស់ ។ ពុំសូវដីពាក់ព័ន្ធរបស់ប្រជាជនទេព្រោះទីតាំងគំរោងស្ថិតនៅក្នុងតំបន់ការពារ ។មានផលប៉ះពាល់ដល់សត្វព្រៃខ្លះ១ តែសត្វទាំងនោះនឹងធ្វើការបំលាស់ ទីទៅតំបន់ស្នូលដែនជំរកសត្វព្រៃភ្នំណាមល្យេវ ។បើតាមការថ្លឹងថ្លែងគួរតែមានការវិនិយោគពីព្រោះថាមានផលចំណេញជាង ។ | លោកសូមអោយក្រុមហ៊ុនវិនិយោគចុះមកសំរបសំរួលជាមួយប្រជាជនផ្ទាល់និងធ្វើការ វិនិយោគតាមកិច្ចសន្យាជាមួយរាជរដ្ឋាភិបាលអោយបានត្រឹមត្រូវ ។ |
| លោក **អេង ប៊ុនហ៊ាង** ប្រធាន | លោកបានដឹងពីវត្តមានគំរោងនេះ និង ឯកភាពលើគំរោងវិនិយោគនេះ ព្រោះបើមិនវិនិយោគទេ ដីតំបន់នោះនឹងមាន | ក្រុមហ៊ុនទទួលប្រជាជនមូលដ្ឋានដើម្បីអោយចូលបំរើការងារក្នុងក្រុមហ៊ុន ។ សូម |

| | | |
|---|---|---|
| មន្ទីរកសិកម្ម ខេត្តមណ្ឌលគិរី | ការកាប់រានយកដីធ្វើកម្មសិទ្ធ។ គំរោងវិនិយោគនេះនឹងផ្តល់ផលប្រយោជន៍ ជូនរដ្ឋ និងការងារជូនប្រជាជន។ ទីតាំងក្រុមហ៊ុនវិនិយោគនេះ មានដីស្រែពាក់ព័ន្ធរបស់ប្រជាជនតិចតួច ប៉ុណ្ណោះនិងមានការប៉ះពាល់ដល់ធនធានព្រៃឈើខ្លះដែរ។ | អោយខាងក្រុមហ៊ុនធ្វើការកាត់ដីស្រែចំការពាក់ព័ន្ធចេញអោយបានសមស្រប និងសូម ខាងជួយធ្វើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗក្នុងភូមិ-ឃុំ។ |
| - លោកស្រី **បេង រ៉ែន** ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តមណ្ឌលគិរី | មន្ទីរបានដឹងពីវត្តមាន របស់គំរោងវិនិយោគនេះ។ការវិនិយោគនឹងផ្តល់ផលប្រយោជន៍ជូនរដ្ឋនិងផ្តល់ការងារជូនប្រជាជន។ មានប៉ះពាល់ខ្លះដល់ដីប្រជាជនពីព្រោះធ្លាប់មាន ភូមិចាស់នៅក្បែរនោះ។ ស្រុកពេជ្រាដានិងស្រុកអូររាំង មិនទាន់បានចេញប័ណ្ណកម្មសិទ្ធដីធ្លីនៅឡើយទេ។ | លោកស្រីសូមអោយក្រុមហ៊ុនដំណើរការទៅតាមការអនុញ្ញាតរបស់រដ្ឋាភិបាល និងកាត់ដីប្រជាជនកាន់កាប់ស្របច្បាប់ចេញពីក្នុងតំបន់គំរោងវិនិយោគរបស់ក្រុមហ៊ុន។ |
| - លោក **កែប កត់** នាយរងខណ្ឌរដ្ឋបាលព្រៃឈើ | លោកមិនបានដឹងពីគំរោងវិនិយោគនេះទេ ។ ក្នុងតំបន់គំរោងនេះសំបូរទៅដោយព្រៃល្បោះ ប៉ុន្តែលោកមិនអាច បញ្ជាក់អោយបានច្បាស់ រីឯសត្វព្រៃមានដូចជា ឈ្លូស និង ជ្រូកព្រៃ។ល។ទីតាំងគំរោងនេះ អាចមានផល ប៉ះពាល់ទៅលើដីប្រជាជនដែរ និងមានការទន្ទ្រានយកដីតិចតួច។ | |
| - លោក **អ៊ុំ វណ្ណសុភ:** នាយផ្នែករដ្ឋបាលព្រៃឈើ សែនមនោរម្យ | លោកបានដឹង និង ឯកភាពលើគំរោងវិនិយោគរបស់ក្រុមហ៊ុននេះ។ លោកមិនបានដឹងពីស្ថានភាពច្បាស់ទេដោយសារតែពីមុន ទីតាំងនេះស្ថិតនៅក្នុង ដែនជំរកសត្វព្រៃភ្នំណាមលៀរ គ្រប់គ្រងដោយកសួងបរិស្ថាន។ មិនមានប្រភេទសត្វកំរទេគឺមានតែឈ្លូសនិងជ្រូកព្រៃជា។ល។ លោកបានបន្តទៀតថា ចំពោះដីព្រៃរិចរិលដែលមានតំលៃសេដ្ឋកិច្ចទាប ត្រូវបានយកទៅវិនិយោគដើម្បីយកចំណូលជូនរដ្ឋ និងប្រជាជន។ | លោកសូមអោយក្រុមហ៊ុនធ្វើការវិនិយោគគោរពទៅតាមលក្ខន្តិកៈជាមួយរដ្ឋាភិបាល និងសហការជាមួយអាជ្ញាធរពាក់ព័ន្ធ និងឈើដែលក្រុមហ៊ុនឈូសឆាយ រដ្ឋបាលព្រៃឈើសូមអោយក្រុមហ៊ុនប្រមូល ទុកដើម្បីអោយរដ្ឋបាលព្រៃឈើ វាយតំលៃហើយបង់ពន្ធជូនរដ្ឋ។ |
| - លោក **ហួត ពិសិដ្ឋ** នាយកដែនជំរកសត្វព្រៃភ្នំណាមលៀរ | លោកបានដឹងពីវត្តមានគំរោង តាមរយៈឯកសារដែលមានស្រាប់ពីនាយកដែនជំរកសត្វព្រៃ ចាស់។ លោកគាំទ្រ ទៅលើការអភិឌ្ឍន៍នេះ ពីព្រោះវាជាគោលការណ៍របស់រដ្ឋាភិបាល ហើយម្យ៉ាងទៀតខាងក្រសួងក៏បានចុះមកសិក្សាពី ទីតាំងមុនសំរេចអោយក្រុមហ៊ុនអភិវឌ្ឍន៍។ ចំពោះផលប៉ះពាល់លោកមិនអាចសន្និដ្ឋានបាន ពីព្រោះលោកទើបតែមកកាន់តំណែងថ្មី។ លោកបន្តទៀតថា ចំណែកផលប្រយោជន៍ក្រុមហ៊ុនផ្តល់ | លោកនាយកដែន សូមឱ្យក្រុមហ៊ុនមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយដែន និងផ្តត់ផ្គង់ដល់ដែន ដើម្បីធ្វើការអភិរក្សបរិស្ថានជុំវិញដែន។ |

Draft

| | | |
|---|---|---|
| | អោយប្រជាជននៅក្នុងមូលដ្ឋាននោះគឺ ជួយឱ្យធ្វើជាកម្មករក្នុងក្រុមហ៊ុន ដើម្បីឱ្យជីវភាពធូរធារ និងបង្កើតហេដ្ឋារចនាសម្ព័ន្ធថ្មីទៀត ។ | |
| ខ. អាជ្ញាធរ | | |
| - ឯកឧត្តម **ញ៉ាំ វ៉ាង ចាន់** អភិបាលរងខេត្តមណ្ឌលគិរី | ឯកឧត្តមបានដឹង និងឯកភាពលើគំរោងវិនិយោគរបស់ក្រុមហ៊ុននេះ ។ ដីនៅតំបន់នេះគួរតែអភិវឌ្ឍន៍ប្រសើរជាងទុកដីព្រៃដែលមានតំលៃសេដ្ឋកិច្ចតិចតួចព្រោះគំរោងនឹងផ្តល់ប្រយោជន៍អោយប្រជា ជនមានការងារធ្វើ និងផ្តល់ចំណូលជូនរដ្ឋ ។ ប៉ុន្តែគំរោងវិនិយោគនេះមានផលប៉ះពាល់ទៅលើដីព្រៃ នៅក្នុងដែនជំរកសត្វព្រៃភ្នំណាមលៀរ ។ | សូមអោយក្រុមហ៊ុនជ្រើសរើសប្រជាជននៅក្នុងតំបន់បំរើការក្នុងក្រុមហ៊ុន និងសូមអោយក្រុមហ៊ុនរកដំណោះស្រាយសមស្របជូនប្រជាជនដោយ ជៀសវាងនូវទំនាស់ ។ |
| លោក **មើល សឿន** អភិបាលស្រុកពេជ្រាដា | លោកឯកភាពលើការវិនិយោគនេះ ព្រោះជួយលើកកំពស់សេដ្ឋកិច្ចជាតិ ប្រជាជនមានការងារធ្វើ អភិវឌ្ឍន៍ភូមិ-ឃុំ ដីដែលគ្មានគំរបព្រៃមានគំរប ព្រៃឡើងវិញ ប៉ុន្តែក្រុមហ៊ុនត្រូវសិក្សាពីដីពាក់ព័ន្ធអោយច្បាស់លាស់ ។ ស្រុកទទួលស្គាល់ដីប្រជាជនដែលបានតាំងទីលំនៅតាំពីឆ្នាំ១៩៧៩ ។ ប្រភេទសត្វព្រៃមានដូចជា សត្វឈ្លូស និងជ្រូកព្រៃតិចតួច ។ | លោកសូមអោយក្រុមហ៊ុនគ្រប់គ្រងកាក់សំណល់អោយបានល្អ និងសហការជាមួយអាជ្ញាធរពាក់ព័ន្ធ និងប្រជាពលរដ្ឋ ។ សូមអោយក្រុមហ៊ុនរក្សា ព្រៃតំណម ព្រៃខ្មោច និងទទួលយកប្រជាជនក្នុងភូមិធ្វើជាកម្មករអោយអស់ពីលទ្ធភាព ។ |
| លោក **កេង ញ៉ក់** មេឃុំប៊ូស្រា | លោកឯកភាពចំពោះការវិនិយោគនេះ ដោយសារជួយបង្កើនការងារអោយប្រជាជន និងជួយកសាងនូវហេដ្ឋារចនាសម្ព័ន្ធផ្សេងៗប៉ុន្តែខាងក្រុមហ៊ុនវិនិយោគត្រូវសិក្សាពីផលប៉ះពាល់បរិស្ថានអោយបានច្បាស់ពីផលប៉ះពាល់ដល់ដីស្រែចំការចាស់របស់ប្រជាជន ។ទីតាំងគំរោងនេះមានប្រជាជនប្រមាណជា ៨២គ្រួសារ ។ មិនសូវ សំបូរព្រៃឈើទេ រីឯសត្វព្រៃមានសំបូរជ្រូកព្រៃ និងផ្ទងតូច ។ | សំណូមពរអោយក្រុមហ៊ុនវិនិយោគសិក្សាពីផលប៉ះពាល់បរិស្ថានក៏ដូចជាបញ្ហាប៉ះពាល់ដីចំការប្រជាជនឱ្យបានច្បាស់លាស់ ។ |
| លោក **យ៉ង ផល** មេភូមិពូលុ | លោកមិនបានដឹងពីគំរោងវិនិយោគនេះទេ ។ ប៉ះពាល់ដីស្រែចំការ ដីបំរុងទុក ដីព្រៃតំណម ៤កន្លែង និងដីព្រៃខ្មោច២កន្លែង ។ លោកឯកភាព ចំពោះគំរោងវិនិយោគនេះ បើខាងក្រុមហ៊ុនវិនិយោគដោះស្រាយបញ្ហាដីធ្លីប្រជាជនអោយសមស្របដោយពិភាក្សាជាមួយប្រជាជនផ្ទាល់តែម្តង ដូចជាកាត់ដី | សំណូមពរអោយក្រុមហ៊ុនជ្រើសរើសកំលាំងពលកម្មក្នុងតំបន់និងសូមអោយក្រុមហ៊ុនវិនិយោគកាត់ចេញផ្ទៃដីពាក់ពន្ធ័របស់ប្រជាជន ។ |

Draft

| | | |
|---|---|---|
| | ចេញ រឺក៏សហការដាំបង្ខាស់ជាមួយ ប្រជាជន។ ព្រៃតំណម និង ព្រៃខ្លោច ក្រុមហ៊ុនវិនិយោគត្រូវពិភាក្សាចាស់ទុំក្នុងភូមិដើម្បី រកដំណោះស្រាយ ។ | |
| លោក **កុយ សុម៉ាលី** មេភូមិឡាំមេះ | លោកបានដឹង និងពេញចិត្តអោយមានក្រុមហ៊ុនវិនិយោគ ព្រោះនឹងជួយលើកស្ទួយជីវភាពប្រជាជន។ ម្រោងវិនិយោគ មានការប៉ះពាល់ដល់ដីស្រែចំការ ព្រៃតម និងព្រៃខ្លោចរបស់ ប្រជាជន។ | សូមអោយក្រុមហ៊ុនសហការណ៍ដាំបង្ខាស់ ជាមួយប្រជាជន និងធ្វើការដោះដូរ ដីធ្លី ពាក់ព័ន្ធរឺទិញពីប្រជាជនក្នុងតំលៃសមរម្យ និងទទួលយកប្រជាជនក្នុងភូមិធ្វើជាកម្ម-ករព្រមទាំងជួយកសាងហេដ្ឋារចនាសម្ព័ន្ធ ក្នុងភូមិ ។ |
| លោក **ម្រូប កុំផា** មេភូមិប៊ូស្រា | លោកមិនដឹងពីវត្តមានគំរោងវិនិយោគនេះទេ។ មានការ ប៉ះពាល់ដល់ ដីស្រែ-ចំការរបស់ប្រជាជន ចំនួន ១២ គ្រួសារ ព្រៃខ្លោច ១ កន្លែង និងព្រៃ តំណម ១ កន្លែង សរុប ៤ហត។ ដំណោះស្រាយ សងជាដីធ្លីជូនប្រជាជន រឺទិញពីប្រជាជន រឺធ្វើការសហការណ៍ជាមួយប្រជាជនដាំបង្ខាស់។ ព្រៃតំណម និងដីព្រៃខ្លោចក្រុមហ៊ុនត្រូវទុកជូនប្រជាជនព្រៃ ក្នុងតំបន់។ លោកមិនអាចសំរេចចិត្តឯកភាព រឺមិនឯកភាពបានទេគឺ អាស្រ័យលើប្រជាជនដែលរស់នៅក្នុងភូមិទាំងមូល។ | សំណូមពរអោយក្រុមហ៊ុនវិនិយោគចុះទៅ មានការប៉ះពាល់ដល់ដីធ្លីរបស់ប្រជាជន ផ្ទាល់ហើយវាស់វែងនិងកាត់ចេញដីប៉ះ ពាល់ទាំងនោះចេញអោយបានត្រឹមត្រូវ ។ |
| លោក **ស្រេង អៀច** មេភូមិពូទឹត | ទីតាំងនេះមានការប៉ះពាល់ដល់ដីចំការប្រមាណជា ២០គ្រួសារ នៅតំបន់ចាប់ពីអូររកាឡើងទៅ និង មានប៉ះពាល់ ដល់ដីព្រៃ ខ្លោច និងព្រៃតំណមរបស់ ប្រជាជនដែរ។ ខាងក្រុមហ៊ុន វិនិយោគត្រូវធ្វើការ ពិភាក្សាជាមួយប្រជាជនផ្ទាល់ដើម្បីដោះ ស្រាយបញ្ហាដីធ្លី ។ | សូមអោយថ្នាក់លើជួយចុះមកធ្វើការ ចរចារពន្យល់និងសម្រុះសម្រួលដើម្បី អោយប្រជាជនបានយល់និងសហការណ៍ ជាមួយក្រុមហ៊ុនវិនិយោគ ។ |
| លោក **មឿង ឃ្មីរ** មេភូមិពូរាំង | លោកមិនដឹងពីវត្តមានរបស់ក្រុមហ៊ុនវិនិយោគនេះទេ ។ មាន ប៉ះពាល់ដល់ដីចំការរបស់ប្រជាជនចំនួន ១៩គ្រួសារ ព្រៃតំណម ៣កន្លែង និងព្រៃខ្លោច ២កន្លែង។ ប្រជាជនមានបំណងដាំ បង្ខាស់ជាមួយក្រុមហ៊ុន និងសំរាប់ព្រៃតំណម និងព្រៃខ្លោច គឺត្រូវទុកដីព្រៃទាំងនោះអោយនៅដដែល។ លោកឯកភាព ចំពោះគំរោង វិនិយោគប្រសិន បើក្រុមហ៊ុនធ្វើការដោះស្រាយ បញ្ហាដីធ្លីពាក់ព័ន្ធបានសមស្រប ។ | សំណូមពរអោយក្រុមហ៊ុនដោះស្រាយការ ប៉ះពាល់ទាំងឡាយទៅតាមការស្នើរសុំ របស់ប្រជាជននិងសូមអោយខាងក្រុមហ៊ុន វិនិយោគជ្រើសរើសយកប្រជាជនក្នុងភូមិ ទៅបំរើការក្នុងក្រុមហ៊ុនអោយបានច្រើន ។ |

Draft

| | | |
|---|---|---|
| លោក **ស្រត ឡាយ** មេភូមិពូចារ | មានប្រជាជនចំនួន៣៩គ្រួសារ ដែលមានដីពាក់ព័ន្ធ នៅក្នុងទីតាំងគំរោងវិនិយោគនេះ។ ប៉ុន្តែអាចនៅមានប្រជាជនដែលមានដីពាក់ព័ន្ធច្រើនជាងនេះទៀត។ មានដីព្រៃខ្មោចរបស់ប្រជាជនភូមិពូទឹត ប៉ុន្តែស្ថិតក្រោម ការគ្រប់គ្រងរបស់មេភូមិពូចារ។ ដំណោះស្រាយស្ថិតនៅលើប្រជាជន រីឯព្រៃតំណម និងព្រៃខ្មោចត្រូវទុកអោយប្រជាជន។ ការសំរេចចិត្តឯកភាពអាស្រ័យទៅលើប្រជាជន។ | សូមអោយក្រុមហ៊ុនសហការណ៍ជាមួយប្រជាជនធ្វើការសម្របសម្រួលជាមួយនឹងសំណូម ពរប្រជាជនអោយបានសមស្រប និងកាត់ដីស្រែប្រជាជនចេញមុនឈុសឆាយនិងសូមអោយក្រុមហ៊ុនរើសកម្មករក្នុងស្រុកធ្វើការក្នុងក្រុមហ៊ុន។ |
| លោក **ខាំ ដារ៉ា និង ស្រែម កែម** អភិបាលរងស្រុកអូររាំង | លោកបានដឹង និងឯកភាពលើ គំរោងវិនិយោគ នេះព្រោះផ្តល់ផលប្រយោជន៍ជាច្រើនដល់ប្រទេសជាតិ។ ដើម្បីបញ្ចៀសទំនាស់ដីធ្លី ខាងក្រុមហ៊ុនត្រូវកសាងក្រុមការងារ ដែលមានមន្ត្រីជំនាញពាក់ព័ន្ធ អាជ្ញាធរដែនដីចូលរួមចុះទៅសិក្សាដល់ទីតាំងផ្ទាល់ជាមួយប្រជាជននៅទីតាំងនោះ ដើម្បីកំណត់ឱ្យបានច្បាស់នូវផលប៉ះពាល់នានា។ | ប្រសិនបើការសិក្សាទៅហើយឃើញថាមានការប៉ះពាល់ដល់ប្រជាជនស្រុកអូររាំង លោកសូមអោយខាងក្រុមហ៊ុនមានគោលការណ៍ ដោះស្រាយអោយបានសមស្រប។ |
| លោក **សម វ៉ាន្នី** មេឃុំដាក់ដាំ | លោកមានការឯកភាពលើ គំរោងអភិវឌ្ឍន៍។ គំរោងនេះនឹងផ្តល់ផលប្រយោជន៍ ដល់ប្រជាជន ប៉ុន្តែត្រូវធ្វើការកាត់ចេញនូវផ្ទៃដី ប៉ះពាល់របស់ប្រជាជន។គំរោងវិនិយោគនេះមិនមានការប៉ះពាល់ដីធ្លីប្រជាជន។ឃុំដាក់ដាំទេ។ ចំពោះធនធានព្រៃឈើ និងសត្វព្រៃមិនមានការប៉ះពាល់ជាធំ ដុំជាដុំកំភួននោះទេ។ | សូមអោយក្រុមហ៊ុនវិនិយោគមុននឹងវិនិយោគត្រូវពិភាក្សាជាមួយអាជ្ញាធរ និងចាស់ ព្រឹទ្ធាចារ្យ និងប្រជាជនមូលដ្ឋាន។ សូមអោយក្រុមហ៊ុនវិនិយោគរក្សាទុកដីស្រែ-ចំការ ដីព្រៃតំណម ដីព្រៃខ្មោច និងដីព្រៃបំរុងទុកដែលក្រុមហ៊ុនបានសិក្សាទៅឃើញ ថាមានការប៉ះពាល់។ |

Draft

### តារាង ៥.២ : ការសង្ខេបពីដីពាក់ព័ន្ធនិងសំណូមពររបស់ប្រជាជន

| ប្រជាជនមូលដ្ឋាន | ដីពាក់ព័ន្ធរបស់ប្រជាជន | សំណូមពរ |
|---|---|---|
| ភូមិពូលុ | -ផ្ទៃដីសរុបមានចំនួន **២៥៩.៥ ហិកតា** របស់ ប្រជាជន **៩២ គ្រួសារ** ដែលរាប់បញ្ចូលទាំង ដីអាស្រ័យផល និងដីចំការវិលជុំ | សូមអោយក្រុមហ៊ុនកាត់ដីដែលពាក់ព័ន្ធប្រជាជនចេញជាមុនសិនមុននឹងធ្វើការវិនិយោគ និងសូមអោយក្រុមហ៊ុនចុះមកកាត់ដីដែលពាក់ព័ន្ធជាមួយប្រជាជនផ្ទាល់ និងសូមអោយក្រុមហ៊ុនទទួលយកប្រជាជន មូលដ្ឋានធ្វើជាកម្មករអោយអស់ពី |

| | | |
|---|---|---|
| | | លិទ្ធភាព។ |
| **ភូមិឡាំម៉េះ** | -ផ្ទៃដីសរុបមានចំនួន **១២៨.៥ ហិកតា** របស់ប្រជាជន ៨៦ **គ្រួសារ** ដែលរាប់បញ្ចូលទាំង ដីអាស្រ័យផល និងដីចំការវិលជុំ | សូមអោយក្រុមហ៊ុនវិនិយោគវាស់វែងដីធ្លីពាក់ព័ន្ធរបស់ប្រជាជន អោយបានត្រឹម--ត្រូវ មុននឹងឈូសឆាយអនុវត្តគំរោង និងសូម អោយក្រុមហ៊ុនវិនិយោគរក្សាដីរបស់ប្រជាជន។ |
| **ភូមិប៊ូស្រា** | -ផ្ទៃដីសរុបមានចំនួន **២៤.៥ ហិកតា** របស់ប្រជាជន **១២ គ្រួសារ** ដែលរាប់បញ្ចូលទាំង ដីអាស្រ័យផល និងដីចំការវិលជុំ | សូមអោយក្រុមហ៊ុនធ្វើការសិក្សាជាមួយភូមិផ្សេងៗដើម្បីកុំអោយមានបញ្ហាទៅ--ថ្ងៃ ក្រោយនិងសូមអោយក្រុមហ៊ុនវិនិយោគ ជ្រើសរើសប្រជាជនក្នុងភូមិធ្វើការអោយ ក្រុមហ៊ុនអោយបានច្រើន។ |
| **ភូមិពូរាំង** | -ផ្ទៃដីសរុបមានចំនួន **១៤០ ហិកតា** របស់ប្រជាជន **១៩ គ្រួសារ** ដែលរាប់បញ្ចូលទាំងដីអាស្រ័យផល និងដីចំការវិលជុំ | មានសំណូមពរអោយក្រុមហ៊ុនវិនិយោគធ្វើ ការទំនាក់ទំនងជាមួយប្រជាជនមុនសិន និងសូមអោយក្រុមហ៊ុនវិនិយោគជ្រើសរើស ប្រជាជនក្នុងភូមិធ្វើបុគ្គលិកអោយអស់ពីលិទ្ធភាព។ |
| **ភូមិពូចារ** | -មានដីពាក់ព័ន្ធប្រជាជន ចំនួន **៣៩គ្រួសារ** ប៉ុន្តែមិនទាន់អាចកំណត់ពីទំហំដីបាននៅឡើយទេ | សូមអោយ ខាងក្រុមហ៊ុនត្រូវចុះធ្វើការ សិក្សាដីធ្លីជាមួយប្រជាជនផ្ទាល់អោយ បានច្បាស់លាស់។ ប្រជាជនមួយចំនួន មានបំណងដាំបង្ហាស់ជាមួយក្រុមហ៊ុន ដោយអោយក្រុមហ៊ុនជួយឈូសឆាយ ផ្តល់ជាពូជ ផ្តល់ជាបច្ចេកទេស និងធ្វើ ការចុះកុងត្រាជាមួយប្រជាជន។ |

បញ្ជាក់ : *ចំនួនផ្ទៃដីដែលពាក់ព័ន្ធរបស់ប្រជាជនអាចនឹងមានច្រើនជាងនេះ*

### ៥.៤.៣ ដំណោះស្រាយរបស់ក្រុមហ៊ុនឆ្លើយតបទៅនឹងសំណូមពរ

- ក្រុមហ៊ុននឹងអនុវត្តទៅតាមបច្ចេកទេសសមស្រប ហើយមានការឯកភាពពីបណ្តាស្ថាប័នជំនាញ

- ក្រុមហ៊ុននឹងសហការជិតស្និតជាមួយអាជ្ញាធរពាក់ព័ន្ធ និងប្រជាជនដើម្បីបជៀសវាល់បញ្ហា ដែលអាចកើតមាន
- ក្រុមហ៊ុននឹងធ្វើការដោះស្រាយ និងសម្របសម្រួលពីបញ្ហាដីធ្លីពាក់ព័ន្ធរបស់ប្រជាជនអោយបានសមរម្យ
- ក្រុមហ៊ុននឹងព្យាយាមជ្រើសរើសប្រជាជនក្នុងតំបន់អោយបំរើការងារក្នុងគំរោងអោយអស់ពីលទ្ធភាព
- ក្នុងករណីកើតមានបញ្ហាដែលបណ្តាមកពីក្រុមហ៊ុននោះ ក្រុមហ៊ុននឹងមានវិធានការណ៍សមរម្យដើម្បីធ្វើការ ដោះស្រាយទៅកាន់ប្រជាជន និងឱ្យបានឆាប់រហ័សបំផុត ។

Draft